**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ១៤.០២៦.៥១០.ស.ជ.ណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដកហូតអាជ្ញាបណ្ណគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ អេច-ផេ សឺវីស ម.ក

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនសាធារណជន មេត្តាជ្រាបថា គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ អេច-ផេ សឺវីស ម.ក បានទទួលអាជ្ញាបណ្ណកាលពីថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៥ ដើម្បីធ្វើប្រតិបត្តិការទូទាត់សងប្រាក់។ ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជា បានពិនិត្យឃើញថា គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ អេច-ផេ សឺវីស ម.ក ពុំបានអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា និងបានសម្រេចដកហូតអាជ្ញាបណ្ណពីគ្រឹះស្ថាននេះ កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦ ដោយទុករយៈពេល ១៥ ថ្ងៃ ដើម្បីឱ្យគ្រឹះស្ថានស្វែងរកក្រុមហ៊ុនជម្រះបញ្ជី។ នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦ ធនាគារជាតិនៃកម្ពុជា បានតែងតាំងក្រុមហ៊ុនសវនកម្ម រីចឆ៍ & ផាតនើរ ជាក្រុមហ៊ុនជម្រះបញ្ជីរបស់គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ អេច-ផេ សឺវីស ម.ក។ តាមរយៈការអនុវត្តនីតិវិធីជម្រះបញ្ជី ក្រុមហ៊ុនសវនកម្ម រីចឆ៍ & ផាតនើរ នឹងប្រកាសជូនដំណឹងជាសាធារណៈ យ៉ាងយូរបំផុតត្រឹមដំណាច់ខែមេសា ឆ្នាំ២០២៦ ដើម្បីអនុវត្តនីតិវិធីកំណត់អត្តសញ្ញាណ និងបញ្ជាក់ពីភាពជាម្ចាស់បំណុលស្របច្បាប់។

គួររំលេចផងដែរថា គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ អេច-ផេ សឺវីស ម.ក ពុំមែនជាធនាគារ និងមិនមានសិទ្ធិទទួលប្រាក់បញ្ញើ និងផ្តល់ឥណទាននោះទេ។ ធនាគារជាតិនៃកម្ពុជា នឹងបន្តតាមដានយ៉ាងប្រុងប្រយ័ត្នលើការអនុវត្តការជម្រះបញ្ជីដើម្បីការពារផលប្រយោជន៍អតិថិជន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម សាធារណជន និងអាជ្ញាធរពាក់ព័ន្ធ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ សុក្រ ៨រោច ខែ ចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០២៦

**ទំនាក់ទំនង ៖**
អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា

(៨៥៥) ២៣ ៩៨០ ១៨៤
nbccommunications@nbc.gov.kh | www.nbc.gov.kh
ធនាគារជាតិ នៃកម្ពុជា - National Bank of Cambodia | National Bank of Cambodia
National Bank of Cambodia | nbccambodia
Natonal Bank of Cambodia | nationalbankofcambodia_